# បទបញ្ញត្តិស្តីពីអ្នកហាត់រៀន

**ប្រការទី១ (គោលបំណង)**
បទបញ្ញត្តិនេះ កំណត់នូវអ្វីដែលអ្នកហាត់រៀនមកពីបរទេសត្រូវគោរពក្នុងរយៈពេលការបង្ហាត់ដែលត្រូវប្រតិបត្តិការដោយ The Association for Overseas Technical Cooperation and Sustainable Partnerships (ហៅកាត់ថា AOTS) ជានីតិបុគ្គលទូទៅ
នៅក្នុងគម្រោងអាជីវកម្មនៅប្រទេសអភិវឌ្ឍន៍ដោយសហការគ្នាខាងបច្ចេកវិទ្យា (គម្រោងបណ្តុះបណ្តាលនិងបញ្ជូនអ្នកជំនាញ)
ឬគម្រោងជំនួយបណ្តុះបណ្តាលធនធានមនុស្សដើម្បីនាំចេញបច្ចេកវិទ្យាកាត់បន្ថយកាបូន
(គម្រោងជំនួយបណ្តុះបណ្តាលធនធានមនុស្សដើម្បីជំរុញការនាំចេញបច្ចេកវិទ្យាកាត់បន្ថយកាបូន)។

**ប្រការទី២ (ការគោរពច្បាប់ បទបញ្ញត្តិផ្សេងៗ)**
២.១ អ្នកហាត់រៀនត្រូវគោរពច្បាប់នៃប្រទេសជប៉ុននិងបទបញ្ញត្តិផ្សេងៗដែល AOTS និងក្រុមហ៊ុនទទួលបានកំណត់ដោយស្មោះត្រង់។

២.២ អនុលោមតាមខដែលចែងខាងលើ អ្នកហាត់រៀនពុំត្រូវធ្វើការងារ
ផ្សេងៗខាងក្រៅ ឬក្រៅម៉ោងទេ។

**ប្រការទី៣ (ការទំនាក់ទំនងមុនមកដល់ប្រទេសជប៉ុន)**
អ្នកហាត់រៀនដែលដាក់ពាក្យមកពីក្រុមហ៊ុននៅបរទេស
ត្រូវផ្តល់ដំណឹងទៅAOTSអំពីការព្រមព្រៀងគោរពតាមច្បាប់ប្រទេសជប៉ុននិងបទបញ្ញាទាំងឡាយ ថ្ងៃមកដល់ប្រទេសជប៉ុន និងថ្ងៃត្រលប់ទៅវិញ ដោយដាក់លិខិតព្រមព្រៀងលក្ខខ័ណ្ឌ
សំណៅចម្លងសំបុត្រយន្តហោះនិងវិក្កយបត្រទិញសំបុត្រយន្តហោះទៅកាន់AOTSមិនលើសពីរសប្តាហ៍មុនថ្ងៃចាប់ផ្តើមវគ្គបណ្តុះបណ្តាល។

**ប្រការទី៤(ការមកដល់ប្រទេសជប៉ុន)**
អ្នកហាត់រៀនត្រូវមកដល់ប្រទេសជប៉ុនឲ្យបាន១ថ្ងៃមុនចាប់ផ្តើមវគ្គបណ្តុះបណ្តាល។ យ៉ាងណាមិញ
អ្នកហាត់រៀនអាចមកដល់ប្រទេសជប៉ុន២ថ្ងៃមុនវគ្គបណ្តុះបណ្តាលចាប់ផ្តើម
ក្នុងករណីAOTSបានទទួលស្គាល់ថាមានហេតុផលមិនអាចជៀសបាន។

**ប្រការទី៥ (គម្រោងនៃការបង្ហាត់និងការចូលរួម)**
៣.១ អ្នកហាត់រៀនត្រូវខំប្រឹងហាត់រៀនតាមគម្រោងនៃការបង្ហាត់ដែល AOTS បានរៀបចំឬក្រុមហ៊ុនទទួលបានរៀបចំហើយបានទទួលការអនុម័តដោយ AOTS ។
៣.២ អ្នកហាត់រៀនត្រូវចូលរួមរាល់ការបង្ហាត់ទាំងអស់ លើកលែងតែមានមូលហេតុចៀសពុំបានដូចជាសុខភាពមិនល្អ ។ល។

**ប្រការទី៦ (លក្ខខ័ណ្ឌការងារ )**
អ្នកហាត់រៀនអាចទទួលប្រាក់ឧបត្ថម្ភនិងសេវាកម្មស្របតាមកំរិតដែល AOTS កំណត់ ។

**ប្រការទី៧ (បំណងប្រាថ្នាឬការជំទាស់របស់អ្នកហាត់រៀន)**
អ្នកហាត់រៀនអាចដាក់ពាក្យស្តីពីបំណងប្រាថ្នា ឬការជំទាស់ ដើម្បីកែលម្អនូវការបង្ហាត់ឬលក្ខខ័ណ្ឌការងារ ។ល។ AOTS នឹងចាត់វិធានការចាំបាច់តាមដែលអាចធ្វើបានចំពោះពាក់ដាក្យដែលដាក់នោះ ប្រកបដោយមានការពិភាក្សាភ្លាមជាមួយនិងភាគីពាក់ព័ន្ធ ។
ក៏ប៉ុន្តែអ្នកហាត់រៀនត្រូវ គោរពការសម្រេចចិត្តនៅទីបំផុតរបស់ AOTS ។

**ប្រការទី៨ (ការប្រុងប្រយ័ត្នសុវត្ថិភា។ល។)**
៦.១ អ្នកហាត់រៀនត្រូវរស់នៅប្រកបដោយយកចិត្តទុកដាក់លើសុខភាពនិងសុវត្ថិភាពយ៉ាងល្អ ដើម្បីកុំអោយប៉ះពាល់ដល់ការបន្តហាត់រៀន ។

៦.២ តាមទស្សនៈខដែលបានចែងខាងលើ អ្នកហាត់រៀនពុំត្រូវបើកបររថយន្ត(រួមទាំងម៉ូតូ) ឬជិះកង់ទេ។ ក៏ប៉ុន្តែ ចំពោះការជិះកង់នោះ អាចយកប្រើបាន នៅពេលក្រុមហ៊ុនទទួលផ្តល់ការអប់រំអំពីសុវត្ថិភាពនិងបំពេញនីតិវិធីការធានារ៉ាប់រង។ល។ ក្នុងករណីពុំមានសេវាដឹកជញ្ជូនសាធារណៈសមរម្យរវាងកន្លែងស្នាក់នៅនិងកន្លែងហាត់រៀន ហើយមានការលំបាកលើក្នុងការធ្វើដំណើរទៅមកដោយមធ្យោបាយផ្សេងទៀត។

**ប្រការទី៩ (ទីស្នាក់នៅ)**
៧.១ អ្នកហាត់រៀនត្រូវស្នាកនៅទីកន្លែងដែល AOTS ឬក្រុមហ៊ុនទទួលបានកំណត់ឬផ្តល់ការអនុញ្ញាត ។
៧.២ ក្នុងករណីពេលអ្នកហាត់រៀនមានប្រាថ្នាចង់ស្នាក់នៅកន្លែងផ្សេងក្រៅពីកន្លែងស្នាក់នៅដែលចែងនៅខខាងលើនោះ ត្រូវសុំការអនុញ្ញាតពី AOTS ទុកជាមុន ។ ក្នុងករណីនៅរយៈពេលការអនុវត្តការហាត់រៀននោះ អ្នកហាត់រៀនត្រូវសុំការអនុញ្ញាតពីAOTS តាមរយៈក្រុមហ៊ុនទទួល ។

**ប្រការទី១០(បម្រាមគោចរនៃមជ្ឈមណ្ឌលបណ្តុះបណ្តាល)**
បម្រាមគោចរនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលគឺត្រឹមម៉ោង១១យប់ ហើយអ្នកហាត់រៀនដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល
ពេលចេញទៅក្រៅត្រូវតែត្រលប់មកវិញមិនឲ្យលើសពីម៉ោងបម្រាមគោចរនេះ។
ករណីមិនអាចត្រលប់មកវិញទាន់ម៉ោងបម្រាមគោចរដោយហេតុផលមិនអាចជៀសបាន
ត្រូវតែមានទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលទុកជាមុន។

**ប្រការទី១១ (ការនាំក្រុមគ្រួសារ)**
អ្នកហាត់រៀនពុំត្រូវនាំឬហៅក្រុមគ្រួសារ អោយមកនៅជាមួយគ្នាទេ ។ ក៏ប៉ុន្តែក្នុង
ករណីមានមូលហេតុចៀសពុំបានដែលអ្នកហាត់រៀនត្រូវហៅក្រុមគ្រួសារនោះអ្នកហាត់រៀនត្រូវតែទទួលការអនុញ្ញាតពី AOTS ទុកជាមុន។ ក្នុងករណីនៅរយៈពេលការអនុវត្តការហាត់រៀននោះ អ្នកហាត់រៀនត្រូវសុំការអនុញ្ញាតពីAOTS តាមរយៈក្រុមហ៊ុនទទួល ។

**ប្រការទី១២ (ចេញពីប្រទេសជប៉ុនសម្រាប់មួយរយៈពេល)**
អ្នកហាត់រៀនពុំត្រូវចេញពីប្រទេសជប៉ុន ។ ក៏ប៉ុន្តែក្នុងករណីមានមូលហេតុចៀសពុំបាន នោះអ្នកហាត់រៀនត្រូវតែទទួលការអនុញ្ញាតពី

AOTSទុកជាមុន។ ក្នុងករណីនៅរយៈពេលការអនុវត្តការហាត់រៀននោះ  អ្នកហាត់រៀនត្រូវសុំការអនុញ្ញាតពី AOTS តាមរយៈក្រុមហ៊ុនទទួល ។

**ប្រការទី១៣ (ការធានារ៉ាប់រង)**

១០.១  អ្នកហាត់រៀនអាចទទួលការព្យាបាលនានាពេទ្យ។ល។ តាមកិច្ចសន្យាធានារ៉ាប់រងសម្រាប់ការធ្វើដំណើរនៅបរទេសដែល AOTS ទិញពីក្រុមហ៊ុនធានារ៉ាប់រងដោយតែងតាំង អ្នកហាត់រៀនជាអ្នកត្រូវគេធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់ដែលតតរំពឹងទុកនិងកើតឡើង ដោយចៃដន្យ (មិនថាទាក់ទង់នឹងការបង្ហាត់ឬក៏អត់ទេ) ។

**១០.២  អ្នកហាត់រៀនត្រូវជំរាបជូនដល់** AOTS

**ដើម្បីទទួលការណែនាំក្នុងករណីមានលទ្ធភាពដែលតំលៃនៃការព្យាបាលអាចហួសពីកំរិតធានារ៉ាប់រងសម្រាប់ការព្យាបាលដែលកំណត់ក្នុងកិច្ចសន្យាធានារ៉ាប់រងនោះ ។ ក្នុងករណីនៅរយៈពេលការអនុវត្តការហាត់រៀននោះ  អ្នកហាត់រៀនត្រូវសុំការជំរាបជូនដល់** AOTS **តាមរយៈក្រុមហ៊ុនទទួល ។**

**១០.៣  ក្នុងករណីដែលអ្នកហាត់រៀនត្រូវសម្រាកនៅមន្ទីរពេទ្យដោយសារជម្ងឺឬមានគ្រោះថ្នាក់ដែលអាចប៉ះពាល់ដល់ការហាត់រៀននោះអ្នកហាត់រៀនត្រូវជំរាបជូនដល់ក្រុមហ៊ុនទទួលឬ** AOTS **ជាបន្ទាន់ ។**

**១០. ៤.** AOTS **មិនទទួលខុសត្រូវចំពោះការខូចខាតផ្សេងៗរបស់អ្នកហាត់រៀនដែលកើតពីគ្រោះថ្នាក់ដូចដែលមានចែងក្នុងទី ១០.១ ខាងលើនៃប្រការនេះ។ល។  ក្រៅពីតម្លៃធានាដែលក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ថ្លៃ ដល់អ្នកហាត់រៀន ។**

**ប្រការទី១៤ (ការខូចខាតដែលបង្កឡើងដោយអ្នកហាត់រៀន)**

**ក្នុងករណីដែលអ្នកហាត់រៀនបង្កការខូចខាតចំពោះ** AOTS **ឬក្រុមហ៊ុនទទួលដោយចេតនាឬដោយការធ្វេសប្រហែសដ៏ធ្ងន់ធ្ងរណាមួយ នោះអ្នកហាត់រៀនអាចត្រូវទាមទារឲ្យ សងលើការខូចខាតនោះវិញពី** AOTS **ឬក្រុម ហ៊ុនទទួល ។**

**ប្រការទី១៥  (ការបាត់បង់សិទ្ធិជាអ្នកហាត់រៀន)**

**១២.១  អ្នកហាត់រៀនអាចបាត់បង់សិទ្ធិជាអ្នកហាត់រៀនបើមានករណីណាមួយដូចចែងខាងក្រោម :**

**(១) ក្នុងករណីដែលអ្នកហាត់រំលោភលើការកំណត់ក្នុងបទបញ្ញត្តិនេះ ។**

**(២) ក្នុងករណីដែលបន្តវីកហាត់ក៏ដោយ អ្នកហាត់រៀនពុំអាចសម្រេចលទ្ធផល រំពឹងទុកដោយខ្វះសមត្ថភាពឬគ្មានការជំរុញចិត្តខ្លួនឬមានឥរិយាបថឬអកប្បកិរិយាមិនល្អក្នុងការហាត់រៀន  ។**

**(៣) ក្នុងករណីដែលអ្នកហាត់រៀនពុំអាចបន្តការហាត់រៀនទៀតដោយសារឈឺឬមានរបួស ។**

**(៤) ក្នុងករណីដែលអ្នកហាត់រៀនបង្ខូចកេរ្តិ៍ឈ្មោះកិត្តិយសឬសេចក្តីជឿទុកចិត្តរបស់** AOTS **។**

**(៥) ក្នុងការណ ដែលមានបញ្ហាដែលចាត់ទុកថាជាករណីដូចខដែលចែងនៅខាងលើក្នុងមាត្រានេះ ។**

**១២.២  ក្នុងករណីដែលការអនុញ្ញាតទទួលអ្នកហាត់រៀនរវាង** AOTS **និងហ៊ុមហ៊ុនទទួលឬការបង្ហាត់បានត្រូវបញ្ចប់នោះអ្នកហាត់រៀននឹងត្រូវបាត់បង់សិទ្ធិជាអ្នកហាត់រៀន ដោយស្វ័យប្រវត្តិ ។**

**១២.៣  ក្នុងករណីដែលអ្នកហាត់រៀនបាត់បង់សិទ្ធិដោយមូលហេតុដូចចែងក្នុងខទាំងទី ១២.១ និង ១២.២ ខាងលើនោះអ្នកហាត់រៀនត្រូវសងប្រាក់ចំណាយទាក់ទងនិងការបង្ហាត់និងការរស់នៅទាំងអស់ឬមួយចំណែកដល់** AOTS **ដោយផ្ទាល់ឬតាមរយៈក្រុមហ៊ុនទទួល ។**

**ប្រការទី១៦(ត្រឡប់ទៅស្រុកវិញ)**

**១៣.១  អ្នកហាត់រៀនត្រូវត្រឡប់ទៅស្រុកវិញភ្លាម នៅពេលដែលការបង្ហាត់បានចប់រួចរាល់ឬបាត់បង់សិទ្ធិជាអ្នកហាត់រៀនលើកលែងតែទទួលការអនុញ្ញាតពី**AOTS **។**

**១៣.២  ក្នុងករណីដែលអ្នកហាត់រៀនបន្តស្នាក់នៅប្រទេសជប៉ុនលើសពី៨ថ្ងៃក្រោយពីបានបញ្ចប់ការបង្ហាត់ដោយគ្មានការអនុញ្ញាតដូចបានចែងក្នុង ខនៅខាងលើនោះ** AOTS **មិនបង់ប្រាក់លើការចំណាយសម្រាប់ត្រឡប់ទៅស្រុក វិញឡើយ។**

**១៣.៣  កំណត់ក្នុងខទី១២.៣នៃប្រការមុនក៏នឹងត្រូវអនុវត្តក្នុងករណីនៃខទី១៣.២ក្នុងប្រការនេះដែរ ។**

**ប្រការទី១៧(វិញ្ញាប័នបត្រ)**

**អ្នកហាត់រៀនអាចទទួលវិញ្ញាប័នបត្រពី** AOTS **យោងទៅតាមកំណត់ក្នុងបទបញ្ញត្តិស្តីពីការផ្តល់ វិញ្ញាប័នបត្រនៅពេលអ្នកហាត់រៀនសម្រេចការហាត់រៀនដែលបានត្រូវរៀបចំនោះដោយជោគជ័យ ។**

**ប្រការទី១៨(រឿងផ្សេងទៀតដែលពុំមានកំណត់នៅក្នុងបទបញ្ញត្តិនេះ)**

**ចំពោះរឿងផ្សេងៗទៀតដែលពុំមានកំណត់នៅក្នុងបទបញ្ញត្តិនេះ ឬកិច្ចការពិបាកផ្សេងទៀត នោះ** AOTS**នឹងកំណត់នៅរាល់ពេល ។**

**អវសានបញ្ញត្តិ**

**បទបញ្ញត្តិនេះចូលជាធរមានពីថ្ងៃទី១ខែមេសាឆ្នាំ២០១៨។**